ឆ្នាំទី១៦ លេខ ៤៧ សប្តាហ៍ទី ៤ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៦ រាជកិច្ច ទំព័រ ៥៤៦៧

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១២៦..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ សម្រាប់ការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០២០ ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា
- បានឃើញព្រះរាជក្រមលេខ នស /រកម /០៣១៥ /០០៣ ចុះថ្ងៃទី ២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៥/០១៥ ចុះថ្ងៃទី ១១ ខែធ្នូ ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១ :** ត្រូវបានបង្កើតគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ អក្សរកាត់ គ.ស.អ សម្រាប់ការពារការចុះឈ្មោះបោះឆ្នោតដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ



www.pheakdeylaw.com

និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ ដែលមានសមាសភាព ដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១. | សម្តេចក្រឡាហោម **ស ខេង** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២. | ឯកឧត្តម **ទៀ បាញ់** | ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ | អនុប្រធាន |
| ៣. | ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤. | ឯកឧត្តម **វង សូត** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៥. | ឯកឧត្តម **អ៊ិត សំហេង** | រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ៦. | ឯកឧត្តម **ប៉ាន សូរស័ក្តិ** | រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧. | ឯកឧត្តម **សុខ ចិន្តា** | អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៨. | ឯកឧត្តម **ឯម សំអាន** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| ៩. | ឯកឧត្តម **ចាយ សាំងយុន** | រដ្ឋលេខាធិការក្រសួងការពារជាតិ | សមាជិក |
| ១០. | ឯកឧត្តមនាយឧត្តមសេនីយ៍ **នេត សាវឿន** | អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ១១. | ឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉ុល សារឿន** | អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ | សមាជិក |
| ១២. | ឯកឧត្តមនាយឧត្តមសេនីយ៍ **សៅ សុខា** | អគ្គមេបញ្ជាការរង និងជាមេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ១៣. | ឯកឧត្តមនាយឧត្តមសេនីយ៍ **ម៉ៅ ម៉ុនណារិន** | អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុនៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៤. | អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត | ជាប្រធានគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត | សមាជិក |

**មាត្រា ២ :** គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍មានភារកិច្ច ដូចតទៅ ៖

- តាមដាន ត្រួតពិនិត្យ និងគ្រប់គ្រងការប្រើប្រាស់កម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ ធានាឱ្យដំណើរការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតថ្នាក់ជាតិ-ថ្នាក់ក្រោមជាតិ ចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៩ តាមនីតិកាល និងអាណត្តិនីមួយៗ ប្រព្រឹត្តទៅប្រកបដោយសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាព គ្មានការភ័យខ្លាច ការបំភិតបំភ័យ ការគម្រាមកំហែង និងគ្មានអំពើហិង្សាផ្សេងៗ ។
- ធ្វើការពិគ្រោះយោបល់ និងចាត់ចែងផ្តល់កិច្ចសហប្រតិបត្តិការផ្នែកសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ រួមទាំងវិស័យការងារផ្សេងៗទៀតតាមសំណើរបស់ គ.ជ.ប ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ពិសេសច្បាប់

ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ផែនការអន្តរស្ថាប័នរបស់ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ និង គ.ជ.ប ក្រមសីលធម៌ និងសេចក្តីណែនាំផ្សេងៗទៀត ដោយឈរលើគោលការណ៍គោរពសិទ្ធិមនុស្ស នីតិរដ្ឋ និងលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

- ធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាព និងអប់រំផ្សព្វផ្សាយគោលការណ៍ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធដល់គ្រប់យន្តការ រចនាសម្ព័ន្ធសន្តិសុខបោះឆ្នោត និងភ្នាក់ងារសន្តិសុខបោះឆ្នោតឲ្យបានជ្រួតជ្រាប និងដើម្បីសហការអនុវត្តធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ សម្រាប់ការបោះឆ្នោតឲ្យមានលក្ខណៈកាន់តែប្រសើរឡើង ប្រកបដោយការទទួលខុសត្រូវខ្ពស់ ។
- ចាត់ចែងគ្រប់គ្រង និងប្រើប្រាស់ធនធានមនុស្ស សម្ភារ ឧបករណ៍បច្ចេកទេស និងមធ្យោបាយគ្រប់ប្រភេទរបស់ក្រសួង /ស្ថាប័ន និងអង្គភាពពាក់ព័ន្ធដែលមានស្រាប់ ក្នុងទិសដៅជម្រុញយុទ្ធនាការការពារការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មី ឆ្នាំ២០១៦ ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ និងការបោះឆ្នោតឲ្យទទួលបានជោគជ័យ ។
- លើកគម្រោងស្នើថវិកាបំប៉នដល់គ្រប់យន្តការ រចនាសម្ព័ន្ធ និងភ្នាក់ងារសន្តិសុខបោះឆ្នោត និងគម្រោងថវិកាសម្រាប់ការផ្គត់ផ្គង់ជាសម្ភារ មធ្យោបាយប្រើប្រាស់ ប្រេងឥន្ធនៈ និងការចំណាយចាំបាច់ផ្សេងៗទៀតបម្រើដល់កិច្ចប្រតិបត្តិការការពារយុទ្ធនាការចុះឈ្មោះបោះឆ្នោត និងការបោះឆ្នោតនីមួយៗដាក់ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងអនុម័ត ។
- ត្រូវធ្វើរបាយការណ៍ជាប្រចាំ ជុំវិញស្ថានការណ៍សន្តិសុខបោះឆ្នោត និងអំពីសកម្មភាពប្រតិបត្តិការរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោតជូនរាជរដ្ឋាភិបាលជ្រាប ។ ក្នុងករណីចាំបាច់ត្រូវរាយការណ៍បន្ទាន់បំពេញភារកិច្ចផ្សេងៗតាមបញ្ញត្តិច្បាប់ជាធរមាន និងតាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល ។
- ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យ និងមានវិធានការដោះស្រាយឲ្យបានត្រឹមត្រូវ និងទាន់ពេលវេលា ។

**មាត្រា ៣ :** គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន ។

គណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ត្រូវមានលេខាធិការដ្ឋានមួយ ជាសេនាធិការ នៅអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលសមាសភាព និងតួនាទីភារកិច្ចរបស់លេខាធិការដ្ឋាននេះ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈបញ្ជាការសន្តិសុខអចិន្ត្រៃយ៍ ។

**មាត្រា ៤ :** គណៈអភិបាលរាជធានី ខេត្ត និងជាគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្តដែលមានស្រាប់ ត្រូវបានកំណត់ជាស្វ័យប្រវត្តិជាយន្តការ និងរចនាសម្ព័ន្ធសន្តិសុខបោះឆ្នោតថ្នាក់ក្រោមជាតិ ដើម្បីគ្រប់គ្រងដឹកនាំបញ្ជា និងត្រួតពិនិត្យទៅលើការអនុវត្តរបស់ភ្នាក់ងារសន្តិសុខបោះឆ្នោត ក្នុងដែនសមត្ថកិច្ចរាជធានី ខេត្តរៀងៗខ្លួន ។ កម្លាំងនគរបាល ឬ/និងកងរាជអាវុធហត្ថ ឬ/និងកងយោធពលខេមរភូមិន្ទដែលមានមូលដ្ឋានឈរជើងនៅក្នុងទឹកដីភូមិសាស្ត្ររាជធានី ខេត្តនីមួយៗ ត្រូវរៀបចំឲ្យបំពេញភារកិច្ចជាភ្នាក់ងារសន្តិសុខបោះឆ្នោត ផ្អែកតាមផែនការដែលបានកំណត់ ។

**មាត្រា ៥ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន





www.pheakdeylaw.com

និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អគ្គស្នងការនគរបាលជាតិ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស អគ្គនាយក នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មិថុនា ឆ្នាំ ២០១៦

នាយករដ្ឋមន្ត្រី



សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**<u>កន្លែងទទួល</u>** ៖

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៦
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ





www.pheakdeylaw.com